**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់មន្ត្រីរាជការក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ៤៣រូប ឱ្យចូលនិវត្តន៍ក្នុងក្របខណ្ឌមុខងារសាធារណៈ ដោយរក្សាមុខតំណែងនយោបាយនៅដដែល រហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|---|---|
| ១ | **សេង លឹមនៅ** | ប | រដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ២ | **ឌុន អ៊ុយ** | ប | រដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៣ | **ញ៉ឹម ម៉ាលី** | ប | អនុប្រធាន និងជាទីប្រឹក្សាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | | | | |
|---|---|---|---|---|---|
| ៤ | ហូ ណូន | ស | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៥ | ពៅ សាមី | ប | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៦ | យុន ជិនកេន | ប | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៧ | លឹម សំគុល | ប | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៨ | សួន សិទ្ធី | ប | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និងជាអគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ៩ | លី គឹមសុខ | ប | នាយកសាលាភូមិន្ទរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១០ | សោម ចិន | ប | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១១ | ជាច សាទី | ប | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១២ | ស្រ៊ី ថាមរុទ្ធ | ប | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៣ | ម្ចាស់ លាស់ | ប | រដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៤ | យី ហេង | ប | អនុប្រធាននាយកដ្ឋាន | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៥ | សុខ ជីវគុណា | ប | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៦ | ជា សុខុម | ប | ទីប្រឹក្សាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៧ | ឌុយ ឆៅ | ប | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៨ | ឌួច ស៊ិទតាណា | ប | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០៨.២០១១ |
| ១៩ | ថេង អាយអានី | ស | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ១ | ០១.០១.២០១២ |
| ២០ | ទេព ដារ៉ុង | ប | ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២១ | ជា គាន | ប | អនុប្រធានអចិន្ត្រៃយ៍ និងជាទីប្រឹក្សាគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២២ | សំ សោភាន់ | ប | ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២៣ | ប៊ូន លឹមហេង | ប | អនុរដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២៤ | សួង លាងហៃ | ប | អគ្គលេខាធិការរង | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២៥ | ស៊ិន សំណាង | ប | ទីប្រឹក្សារាជរដ្ឋាភិបាល | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២៦ | ស៊ុម មាន | ប | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |
| ២៧ | [illegible] គឹមអាន | ប | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ឧត្តមមន្ត្រីថ្នាក់លេខ ២ | ០១.០៨.២០១១ |



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | | |
|---|---|---|---|---|---|
| ២៨ | **សឹង គង់** | ប | អគ្គនាយករង នៃអាជ្ញាធរអប្សរា | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ២៩ | **ខាំពូន កែវមុណី** | ប | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣០ | **ច័ន្ទ តានី** | ប | រដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣១ | **សេង រ៉ុន** | ប | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣២ | **សំ សុខផល** | ប | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣៣ | **ខឹម ចិសិដ្ឋ** | ប | អនុរដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣៤ | **យ៉ាង ប៊ុនម៉េង** | ប | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣៥ | **អ៊ឹង ខេង** | ប | អនុរដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣៦ | **លាភ ចណ្ណាដេន** | ប | អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា | ឧត្តមមន្ត្រីថ្នាក់លេខ ៣ | ០១.០៨.២០១១ |
| ៣៧ | **គឹម សទ្ធាត** | ប | អនុប្រធាននាយកដ្ឋាន | ឧត្តមមន្ត្រីថ្នាក់លេខ ៤ | ០១.០៨.២០១១ |
| ៣៨ | **ឆឹង សុខៃ** | ប | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ៤ | ០១.០៨.២០១១ |
| ៣៩ | **ហ៊ុន ហេង** | ប | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ឧត្តមមន្ត្រីថ្នាក់លេខ ៥ | ០១.០៨.២០១១ |
| ៤០ | **រស់ ចន្ត្រាបុត្រ** | ប | ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា | ឧត្តមមន្ត្រីថ្នាក់លេខ ៥ | ០១.០៨.២០១១ |
| ៤១ | **គង់ អួក** | ប | ប្រធាននាយកដ្ឋាន | ឧត្តមមន្ត្រីថ្នាក់លេខ ៥ | ០១.០៨.២០១១ |
| ៤២ | **តាន់ សំប៊ុន** | ប | អគ្គនាយករងនៃអាជ្ញាធរអប្សរា | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ០១.០៨.២០១១ |
| ៤៣ | **មាសសាឯម ជានី** | ស | អនុរដ្ឋលេខាធិការ | ឧត្តមមន្ត្រីថ្នាក់លេខ ៦ | ០១.០៨.២០១១ |

**មាត្រា ២៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤៖** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស. ១១០៤.៤១៣

លេខ ...៥៩ ច.ល
**ដើម្បីចម្លងចែក**
**រាជធានីភ្នំពេញ ថ្ងៃទី ... ខែ សីហា ឆ្នាំ២០១១**
**អគ្គលេខាធិការរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១*

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១១/៧៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **សារុន ឬទ្ធា** ជា **ទីប្រឹក្សា** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស.១១០៥.៥១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១

លេខ: ៨៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១១
អគ្គលេខាធិការ [illegible] រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១១/៧៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**តែងតាំង**

**លោក ហ្គី អានឌ៉ានិច**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៖ស.១១០៩.៩១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១*

លេខ:៧៦៥ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១១/៧៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ចំពោះ

ព្រះតេជគុណ **ស្រី សុវណ្ណ**

ដែលបានបរិច្ចាគធនធានចូលរួមចំណែកកសាងសមិទ្ធផលនានា

ក្នុងវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅក្នុងខេត្តកំពត

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣១៤..១១០៥.៨១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១

លេខ: ៧៦៦ ច.ល

**ចម្លងចែក**

រាជធានីភ្នំពេញ ,ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១១

**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៩០. អនុក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០០ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងបំពេញការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងគ្រប់គ្រងលើការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេស។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅដូចតទៅ៖

- រកទីផ្សារការងារនិងផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរទៅធ្វើការនៅបរទេស
- លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ
- ធានាសុវត្ថិភាពជូនពលករខ្មែរដែលទៅធ្វើការនៅបរទេស
- រួមចំណែកលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស
- រួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់បន្ថយភាពក្រីក្រ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើបេក្ខជនពលករទេសន្តរប្រវេសន៍ ពលករខ្មែរ និងទីភ្នាក់ងារជ្រើសរើសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- បេក្ខជនពលករទេសន្តរប្រវេសន៍ សំដៅដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានអាយុចាប់ពី១៨ឆ្នាំឡើង ដែលបានដាក់ពាក្យសុំទៅធ្វើការនៅបរទេសនិងកំពុងបំពេញបែបបទជាផ្លូវការតាមរយៈទីភ្នាក់ងារជ្រើសរើសស្របតាមគោលការណ៍របស់ស្ថាប័នមានសមត្ថកិច្ចដែលមានជាអាទិ៍ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។
- ពលករ សំដៅដល់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលស្ថិតនៅគ្រប់ដំណាក់កាលទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាសេវារកការងារឲ្យធ្វើជាមួយទីភ្នាក់ងារជ្រើសរើសរហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។ ទន្ទឹមនឹងនេះ ក៏រាប់បញ្ចូលប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលទៅធ្វើកម្មសិក្សាផងនិងធ្វើការងារផងនៅបរទេស ហើយមានកិច្ចសន្យាត្រឹមត្រូវដែលទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- សេវារកការងារឲ្យធ្វើ សំដៅដល់សេវារកការងារឲ្យធ្វើដោយពេញលេញនៅប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជាស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងច្បាប់ជាធរមាននានានៃព្រះរាជាណាចក្រកម្ពុជានិងប្រទេសទទួលពលករ

- **ទីភ្នាក់ងារជ្រើសរើស** សំដៅដល់នីតិបុគ្គលឯកជនដែលត្រូវបានបង្កើតឡើងត្រឹមត្រូវតាមច្បាប់និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានអនុញ្ញាតជាផ្លូវការដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យទទួលខុសត្រូវក្នុងការផ្តល់សេវារកការងារឲ្យធ្វើដោយពេញលេញនៅបរទេស។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាក្រសួងមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសដោយធ្វើកិច្ចសហការជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## ទីភ្នាក់ងារជ្រើសរើស

**មាត្រា ៦.-**

ទីភ្នាក់ងារជ្រើសរើសពលករខ្មែរទៅធ្វើការនៅបរទេស ត្រូវទទួលបានការអនុញ្ញាតតាមប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដោយឥតបង់ថ្លៃ លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ។

បែបបទក្នុងការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ទីភ្នាក់ងារជ្រើសរើស ត្រូវគោរពច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៧.-**

ដើម្បីទទួលបានការអនុញ្ញាត ទីភ្នាក់ងារជ្រើសរើសត្រូវបំពេញលក្ខខណ្ឌចាំបាច់មួយចំនួនដូចខាងក្រោម៖

ក- ត្រូវមានទីចាត់ការដែលមានអាសយដ្ឋានច្បាស់លាស់ មានបុគ្គលិកបម្រើការងារ សម្ភារៈការិយាល័យ មធ្យោបាយទំនាក់ទំនង និងមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់។

ខ- ត្រូវមានមជ្ឈមណ្ឌលណែនាំតម្រង់ទិសដែលមានទំហំសមស្រប៖

- អគារដែលបំពាក់ដោយឧបករណ៍និងសម្ភារៈសម្រាប់ការងារបំប៉នមុខជំនាញនិងភាសាស្របតាមបទដ្ឋានមុខជំនាញនិងតម្រូវការទីផ្សារការងារ និងសម្រាប់ការងារអប់រំណែនាំតម្រង់ទិសមុនពេលចេញដំណើរតាមគោលការណ៍ណែនាំ
- កន្លែងស្នាក់នៅហូបចុកដែលត្រឹមត្រូវនិងធានាបាននូវសុខភាព អនាម័យ និង

សុវត្ថិភាពល្អ
- បទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែលទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

គ- ត្រូវមានគ្រូសម្រាប់ការបំប៉នមុខជំនាញភាសាស្របតាមបទដ្ឋានមុខជំនាញនិងតម្រូវការរបស់អ្នកទទួលពលករ។

ឃ- ត្រូវចុះកិច្ចសន្យាជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈអំពីកាតព្វកិច្ច និងនីតិវិធីនៃការប្រតិបត្តិសេវាកេការងារឲ្យធ្វើ។

ង- ត្រូវតម្កល់ប្រាក់ធានាត្រឹមត្រូវតាមគោលការណ៍ណែនាំដូចមានចែងក្នុងមាត្រា៨និងមាត្រា១០នៃអនុក្រឹត្យនេះ។

ច- ត្រូវមានតំណាងអចិន្ត្រៃយ៍នៅប្រទេសដែលទទួលពលករ។

**មាត្រា ៨.-**

ក្រោយពីទទួលបានការអនុញ្ញាតតាមប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ ទីភ្នាក់ងារជ្រើសរើសត្រូវតម្កល់ប្រាក់ធានាជាប្រាក់រៀលដែលមានចំនួនសមមូលនឹង១០០ ០០០(មួយសែន)ដុល្លារអាមេរិក នៅក្នុងគណនីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលស្ថិតនៅក្នុងធនាគារណាមួយ។ ឯកសារច្បាប់ដើមនៃការតម្កល់ប្រាក់ធានានេះ ត្រូវយកទៅតម្កល់ទុកនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៩.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចាត់ឲ្យមានការធ្វើអធិការកិច្ចសាមញ្ញនិងអធិការកិច្ចពិសេសចំពោះទីភ្នាក់ងារជ្រើសរើស។

## ជំពូកទី៤
## ការប្រើប្រាស់ប្រាក់ធានា

**មាត្រា ១០.-**

ប្រាក់ធានាដែលបានតម្កល់នៅក្នុងគណនីរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចត្រូវបានដកយកមកប្រើប្រាស់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ចាត់ចែងដោះស្រាយចំពោះករណីសំខាន់ៗមួយចំនួនៈ

ក- ចំពោះករណីប្រធានសក្តិ សង្គ្រាម កលិយុគ ជំងឺរាតត្បាត នៅក្នុងប្រទេសទទួលពលករឬនៅកន្លែងពលករធ្វើការដែលចាំបាច់ត្រូវចល័តពលករទៅរកទីកន្លែងដែលមានសុវត្ថិភាពឬបញ្ជូនពលករមកកាន់មាតុភូមិវិញ ដើម្បីធានាសុវត្ថិភាព ប្រាក់ធានាដែលត្រូវបានដកយកមកប្រើប្រាស់ត្រូវបានបំពេញដោយថវិកាជាតិឬដោយមូលនិធិជំនួយសង្គ្រោះណាមួយ។

ខ- ចំពោះករណីដែលទីភ្នាក់ងារជ្រើសរើសមិនបានគោរពលក្ខខណ្ឌនានានៃកិច្ច

រវាងទីភ្នាក់ងារជ្រើសរើសនិងពលករឬរវាងទីភ្នាក់ងារជ្រើសរើសនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមិនព្រមដោះស្រាយតាមគោលការណ៍សម្របសម្រួលរហូតប៉ះពាល់ដល់ផលប្រយោជន៍របស់ពលករ ប្រាក់ធានាដែលត្រូវបានដកយកមកប្រើប្រាស់ ត្រូវបានបំពេញឲ្យគ្រប់ចំនួនឡើងវិញ ដោយទីភ្នាក់ងារជ្រើសរើសក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ។

**មាត្រា ១១.-**

ទីភ្នាក់ងារជ្រើសរើសអាចស្នើសុំដកប្រាក់ធានាមកវិញបានក្នុងករណីបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ទីភ្នាក់ងារជ្រើសរើសបានបញ្ឈប់ជាស្ថាពរនូវការជ្រើសរើសនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
- ពលករដែលបានបញ្ជូនទៅធ្វើការនៅបរទេស បានត្រឡប់មកមាតុភូមិវិញអស់ហើយ
- ទីភ្នាក់ងារជ្រើសរើសបានដោះស្រាយបញ្ហាជាមួយពលករចប់សព្វគ្រប់។

## ជំពូកទី៥
## ទីផ្សារការងារនិងជំនាញពលករ

**មាត្រា ១២.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវស្វែងរកនិងផ្តល់ការគាំទ្រ លើកទឹកចិត្តក្នុងការស្វែងរកទីផ្សារការងារល្អៗនៅបរទេស សម្រាប់បង្កឱកាសការងារជូនពលរដ្ឋខ្មែរ។

**មាត្រា ១៣.-**

ទីភ្នាក់ងារជ្រើសរើសត្រូវធ្វើកិច្ចសហការជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិក្នុងការពិនិត្យ សិក្សាស្រាវជ្រាវអំពីតម្រូវការកម្លាំងពលកម្មនិងជំនាញការងារ ដើម្បីបង្កឱកាសការងារសម្រាប់ប្រជាពលរដ្ឋខ្មែរ។

**មាត្រា ១៤.-**

ក្នុងលទ្ធភាពសមស្រប ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើកិច្ចសហការជាមួយនឹងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដើម្បីរៀបចំកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទទួលពលករ ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម។

## ជំពូកទី៦
## កិច្ចសន្យា

**មាត្រា ១៥.-**

ក្នុងការជ្រើសរើសនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ទីភ្នាក់ងារជ្រើសរើសត្រូវចុះកិច្ចសន្យានិងអនុវត្តកិច្ចសន្យាឲ្យបានត្រឹមត្រូវ។

កិច្ចសន្យាចាំបាច់មួយចំនួនរួមមាន៖

- កិច្ចសន្យារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើស

- កិច្ចសន្យារវាងទីភ្នាក់ងារជ្រើសរើសនិងពលករខ្មែរ ដែលមានឈ្មោះថាកិច្ចសន្យាសេវារកការងារឲ្យធ្វើ
- កិច្ចសន្យារវាងនិយោជកបរទេសនិងពលករខ្មែរ ដែលមានឈ្មោះថាកិច្ចសន្យាការងារ។

កិច្ចសន្យាការងារត្រូវបញ្ជាក់ឲ្យបានច្បាស់ជាអាទិ៍ អំពីលក្ខខណ្ឌការងារ ស្ថានភាពការងារ ប្រភេទការងារ ផលប្រយោជន៍ដែលទទួលបាន និងអាសយដ្ឋានសំខាន់ៗដែលត្រូវធ្វើការទំនាក់ទំនង។

**មាត្រា ១៦.-**

កិច្ចសន្យារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើស និងកិច្ចសន្យាសេវារកការងារឲ្យធ្វើ ត្រូវធ្វើជាភាសាខ្មែរ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៧.-**

កិច្ចសន្យាការងារត្រូវធ្វើជាភាសាខ្មែរ ភាសាប្រទេសទទួលពលករ និងភាសាអង់គ្លេស ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃប្រទេសទទួលពលករ។

កិច្ចសន្យាទាំងនេះត្រូវបញ្ជូនទៅស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ តាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ១៨.-**

គំរូកិច្ចសន្យាដែលមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

កិច្ចសន្យានេះត្រូវមានហត្ថលេខារបស់អ្នកតំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៧
## ការជ្រើសរើសពលករនិងការណែនាំតម្រង់ទិសមុនចេញដំណើរ

**មាត្រា ១៩.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលខុសត្រូវលើបែបបទនានានិងការពិនិត្យសុខភាពពលករខ្មែរដែលត្រូវចេញទៅធ្វើការនៅបរទេស ស្របតាមការកំណត់របស់ប្រទេសទទួលពលករ។

ពលករខ្មែរដែលបញ្ជូនទៅធ្វើការនៅបរទេសមិនអាចគេចផុតពីកាតព្វកិច្ចយោធាបានទេ។

**មាត្រា ២០.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវផ្តល់ព័ត៌មានដល់ពលករអំពីមធ្យោបាយទាក់ទង អាសយដ្ឋាន លេខទូរស័ព្ទ សម្រាប់ធ្វើទំនាក់ទំនងជាមួយនឹងស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករនិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងពេលណែនាំតម្រង់ទិសមុនចេញដំណើរ។

**មាត្រា ២១.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលខុសត្រូវលើលក្ខខណ្ឌការងារនិងលក្ខខណ្ឌរស់នៅមុននឹងជ្រើសរើសពលករឲ្យទៅធ្វើការនៅបរទេស ដូចជាប្រភេទការងារ ទីកន្លែងធ្វើការងារ ពេលម៉ោងធ្វើការងារ មុខជំនាញ ប្រាក់បៀវត្សរ៍ ប្រាក់បំណាច់ ការធានារ៉ាប់រងសុខភាព កន្លែងស្នាក់នៅ ការដឹកជញ្ជូន សន្តិសុខ សុវត្ថិភាពក្នុងតំបន់ធ្វើការនិងស្នាក់នៅ។

**មាត្រា ២២.-**

រាល់ការឃោសនាផ្សព្វផ្សាយរបស់ទីភ្នាក់ងារជ្រើសរើស ត្រូវធ្វើឲ្យបានត្រឹមត្រូវនិងសព្វគ្រប់ទៅតាមការពិតជាក់ស្តែងដែលពាក់ព័ន្ធនឹងលក្ខខណ្ឌជ្រើសរើស លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍ដែលទទួលបាននៅក្នុងពេលវេលានៃការងារដោយមិនមានការភូតកុហកឬលាក់បាំង។

**មាត្រា ២៣.-**

ក្នុងរាល់កិច្ចដំណើរការវគ្គនិងកម្មវិធីសិក្សាណែនាំតម្រង់ទិសមុនចេញដំណើរ ទីភ្នាក់ងារជ្រើសរើស ត្រូវធ្វើកិច្ចសហការជាមួយនឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងស្ថាប័នពាក់ព័ន្ធ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្តល់វិញ្ញាបនបត្រជូនពលករដែលបានបញ្ចប់វគ្គដោយជោគជ័យ។

**មាត្រា ២៤.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលខុសត្រូវក្នុងការបញ្ជូនពលករឲ្យដល់ទីកន្លែងធ្វើការនៃប្រទេសទទួលពលករតាមកិច្ចសន្យា។

ក្នុងការបញ្ជូនពលករម្តងលើកៗ ទីភ្នាក់ងារជ្រើសរើសត្រូវធ្វើរបាយការណ៍ឲ្យបានច្បាស់លាស់ជូនស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ២៥.-**

នៅរាល់ពេលដែលពលករត្រូវបានបញ្ជូននិងត្រូវបានដាក់ឲ្យធ្វើការរួចហើយ ទីភ្នាក់ងារជ្រើសរើសត្រូវកត់ត្រារាល់ព័ត៌មាននិងទិន្នន័យទាក់ទងនឹងពលករម្នាក់ៗ ក្នុងសៀវភៅបន្ទុកឲ្យបានត្រឹមត្រូវតាមការកំណត់។

សៀវភៅបន្ទុកត្រូវចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ទីភ្នាក់ងារជ្រើសរើសកត់ត្រារាល់ព័ត៌មាននិងទិន្នន័យទាក់ទងនឹងពលករបន្តពីឯកសារនានាដែលត្រូវធានាធ្វើជាផ្លូវការ។

## ជំពូកទី៨
## ការធ្វើមាតុភូមិនិវត្តន៍របស់ពលករ

**មាត្រា ២៦.-**

នៅពេលដែលកិច្ចសន្យាការងាររបស់ពលករ ឈានដល់ទីបញ្ចប់ ហើយពលករមិនបានបន្តកិច្ចសន្យាទៀតទេ ទីភ្នាក់ងារជ្រើសរើស ត្រូវរៀបចំដំណើរការមាតុភូមិនិវត្តន៍របស់ពលករនោះឲ្យបានត្រឹមត្រូវតាមការកំណត់ ដោយត្រូវជូនដំណឹងជាផ្លូវការទៅស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលយ៉ាងតិច៣០( សាមសិប )ថ្ងៃនៃថ្ងៃធ្វើការ មុនការធ្វើមាតុភូមិនិវត្តន៍មួយលើកៗ ដោយបញ្ជាក់ឲ្យច្បាស់អំពីចំនួនឈ្មោះពលករ ពេលវេលា និងច្រកទ្វារព្រំដែនដែលពលករត្រូវឆ្លងកាត់។

**មាត្រា ២៧.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវផ្តល់សេវាសមស្រប ដើម្បីធានាឲ្យពលករបានវិលត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាប្រកបដោយសុវត្ថិភាព។

**មាត្រា ២៨.-**

នៅពេលមកដល់ព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារជ្រើសរើស ត្រូវបញ្ជូនពលករទាំងអស់ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលលិខិតបញ្ជាក់អំពីការងារដែលពលករបានអនុវត្តនៅបរទេស និងយកទៅប្រើប្រាស់តាមលទ្ធភាពដែលអាចប្រើបាន។

## ជំពូកទី៩
## ការដោះស្រាយវិវាទ

**មាត្រា ២៩.-**

វិវាទដែលកើតឡើងរវាងទីភ្នាក់ងារជ្រើសរើសនិងពលករមុនពេលពលករចេញទៅធ្វើការនៅបរទេស ត្រូវដោះស្រាយតាមច្បាប់ស្តីពីការងារនិងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣០.-**

ចំពោះវិវាទដែលកើតឡើងរវាងនិយោជកបរទេសនិងពលករដែលកំពុងធ្វើការនៅបរទេស ទីភ្នាក់ងារជ្រើសរើសនិងស្ថានឯកអគ្គរាជទូតឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសដែលទទួលពលករ ត្រូវចូលរួមដោះស្រាយ។

ក្នុងករណីចាំបាច់ដែលត្រូវមានមន្ត្រីជំនាញរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចូលរួមឬរកមេធាវីដើម្បីការពារក្តីរបស់ពលករ រាល់ការចំណាយជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើស។

## ជំពូកទី១០
## ការបាត់ខ្លួនពលករ

**មាត្រា ៣១.-**

ក្នុងករណីមានការបាត់ខ្លួនពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាសេវាកម្មការងារឲ្យធ្វើ ទីភ្នាក់ងារជ្រើសរើសត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ច ក្រសួងមហាផ្ទៃនិង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៣២.-**

នៅពេលទទួលបានព័ត៌មានស្តីពីការបាត់ខ្លួនពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យា ការងារ ទីភ្នាក់ងារជ្រើសរើសត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូតឬស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១១
## របបសន្តិសុខសង្គម

**មាត្រា ៣៣.-**

ទីភ្នាក់ងារជ្រើសរើស ត្រូវទទួលបន្ទុករៀបចំនិងធានាថា ពលករដែលត្រូវបានបញ្ជូនទៅ ធ្វើការនៅបរទេស ទទួលបានរបបសន្តិសុខសង្គមស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន នៃប្រទេសទទួលពលករ។

**មាត្រា ៣៤.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវត្រួតពិនិត្យតាមដានការអនុវត្តរបស់ ទីភ្នាក់ងារជ្រើសរើសលើការទទួលបាននូវរបបសន្តិសុខសង្គមរបស់ពលករ ព្រមទាំងធ្វើកិច្ច សហប្រតិបត្តិការជាមួយប្រទេសទទួលពលករ។

## ជំពូកទី១២
## ប្រាក់បញ្ញើរបស់ពលករមកកម្ពុជា

**មាត្រា ៣៥.-**

ទីភ្នាក់ងារជ្រើសរើសត្រូវជួយពលករដែលទៅធ្វើការនៅបរទេសក្នុងការបើកនិងការប្រើ គណនីផ្ទាល់ខ្លួននៅក្នុងធនាគារណាមួយដែលមានសុវត្ថិភាព ដើម្បីបង្កលក្ខណៈឲ្យពលកររក្សា ទុកប្រាក់និងផ្ញើមកក្រុមគ្រួសារនៅកម្ពុជាតាមប្រព័ន្ធធនាគារ។

**មាត្រា ៣៦.-**

ក្នុងករណីចាំបាច់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជួយសម្រួលសម្រួលក្នុង ការបើកគណនីនៅធនាគារណាមួយ ដើម្បីផ្ទេរប្រាក់ពីបរទេស។

## ជំពូកទី១៣
## ការលើកសរសើរ

**មាត្រា ៣៧.-**

ទីភ្នាក់ងារជ្រើសរើសណាដែលដំណើរការជ្រើសរើសនិងបញ្ជូនពលករទៅធ្វើការនៅបរទេសបានល្អប្រសើរ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលបាននូវការលើកសរសើរ ស្របទៅតាមកម្រិតនីមួយៗ។

**មាត្រា ៣៨.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវផ្តល់បណ្ណសរសើរដល់ទីភ្នាក់ងារជ្រើសរើសដែលអនុវត្តកិច្ចសន្យាបានល្អ។

## ជំពូកទី១៤
## ទណ្ឌកម្ម

**មាត្រា ៣៩.-**

ទីភ្នាក់ងារជ្រើសរើសណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចតទៅៈ

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរការអនុញ្ញាតជាបណ្តោះអាសន្ន
- ការដកការអនុញ្ញាតជាស្ថាពរ។

**មាត្រា ៤០.-**

ទីភ្នាក់ងារជ្រើសរើសឬជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬច្បាប់ជាធរមាន ឬប្រើប្រាស់មុខងារនិងសមត្ថកិច្ចរបស់ខ្លួនបង្កជាឧបសគ្គ មិនសមស្របចំពោះសកម្មភាពជ្រើសរើសនិងបញ្ជូនពលករទៅធ្វើការនៅបរទេសដោយខុសច្បាប់ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា ៤១.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញសារាចរណែនាំអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព។

**មាត្រា ៤២.-**

អនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៦ . អនក្រ-បក

# អនុក្រឹត្យ
# ស្តីពី
# មគ្គុទ្ទេសក៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីវិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ សម្រាប់បម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យទទួលបាននូវប្រសិទ្ធភាពនិងគុណភាព
- ធានាឲ្យមានការគោរពតាមក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ ព្រមទាំងធានាដល់ការថែរក្សាធនធានធម្មជាតិ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ វប្បធម៌ ប្រពៃណី សិល្បៈ និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរនិងអ្នកបកប្រែភាសាមិនត្រូវបានរាប់បញ្ចូលជាមគ្គុទេសក៍ទេសចរណ៍ទេ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

មគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលប្រកបអាជីពជាអ្នកទទួលជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ជាអាជ្ញាបណ្ណពេញសិទ្ធិឬអាជ្ញាបណ្ណបណ្តោះអាសន្ន។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលត្រូវបានអនុញ្ញាតឲ្យបំពេញការងារនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅគ្រប់គោលដៅទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចណ៍ថ្នាក់តំបន់ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍ តែនៅក្នុងដែនដីនៃរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវតែនៅក្នុងសហគមន៍ប៉ុណ្ណោះ។

អ្នកឧទ្ទេសនាម សំដៅដល់បុគ្គលដែលត្រូវបានប្រគល់ភារកិច្ចឲ្យពន្យល់ អធិប្បាយជូនភ្ញៀវនៅតាមប្រាសាទឬតាមសារមន្ទីរ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

ក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស។

ក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិនិងថ្នាក់តំបន់ ដល់មគ្គុទ្ទេសក៍ទេសចរណ៍។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិងថ្នាក់សហគមន៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ ដោយមានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាសេនាធិការ។

**មាត្រា ៦.-**

ការគ្រប់គ្រង ការផ្តល់អាជ្ញាបណ្ណ និងការបែងចែកកម្រិតមគ្គុទ្ទេសក៍ទេសចរណ៍ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិងថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ៧.-**

ក្រសួងទេសចរណ៍មានសិទ្ធិចាត់តាំងមន្ត្រីជំនាញឲ្យចុះធ្វើអធិការកិច្ចត្រួតពិនិត្យសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍តាមគោលដៅទេសចរណ៍នានានៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ច មន្ត្រីជំនាញនៃក្រសួងទេសចរណ៍អាចសហការនិងសម្របសម្រួលជាមួយនគរបាលទេសចរណ៍ មន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។ ទំនាក់ទំនងរវាងមន្ត្រីអធិការកិច្ចទេសចរណ៍និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## វិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
### ផ្នែកទី១
### អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ៨.-**

លក្ខណវិនិច្ឆ័យសម្រាប់ការពិនិត្យវាយតម្លៃនិងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានដូចខាងក្រោម៖

ក- ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរនិងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

ខ- មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍។

គ- លិខិតបញ្ជាក់កិរិយាមារយាទ ដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅសម្រាប់ការសុំអាជ្ញាបណ្ណទេសចរណ៍។

ឃ- វិញ្ញាបនបត្រពិនិត្យសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនិងមានការឯកភាពពីក្រសួងទេសចរណ៍។

ង- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត។

**មាត្រា ៩.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍។

**មាត្រា ១០.-**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍នៅក្រសួងទេសចរណ៍ឬនៅរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមប្រភេទនៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍។

ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១១.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មានសុពលភាពអប្បបរមា០១(មួយ)ឆ្នាំ គិតពីថ្ងៃចេញអាជ្ញាបណ្ណ។ សុពលភាពជាក់លាក់នៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចធ្វើការផ្ទេរឬការលក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គលនិងបទពិសោធរបស់ម្ចាស់អាជ្ញាបណ្ណ។

**មាត្រា ១២.-**

នៅពេលមានការខូចខាតឬការបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់និងមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតាឡើងវិញក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាតឬបាត់បង់។ ក្នុងករណីនេះ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវរាយការណ៍ជាបន្ទាន់ជូនសមត្ថកិច្ចដែលនៅជិតបំផុត អំពីមូលហេតុនៃការខូចខាតឬការបាត់បង់ដើម្បីទទួលបាននូវលិខិតបញ្ជាក់ដឹងឮពីសមត្ថកិច្ចសម្រាប់កាន់តាមខ្លួនពេលធ្វើអាជីវកម្មមុនពេលទទួលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

នៅពេលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវបានលុបឬព្យួរ ឬពេលមគ្គុទ្ទេសក៍ទេសចរណ៍ឈប់ប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវប្រគល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជូនក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិវិញ។

## ផ្នែកទី២
## ការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៣.-**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៤.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក- គោរព អនុវត្តឲ្យបានត្រឹមត្រូវនូវក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍

ទេសចរណ៍ព្រមទាំងប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

ខ- ប្រតិបត្តិត្រឹមត្រូវតាមវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដោយមិនដើរតួនាទីជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍។

គ- មិនត្រូវទាមទារកម្រៃឬផលប្រយោជន៍ពីអ្នកលក់ឬពីអ្នកផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។

ឃ- មិនត្រូវធ្វើសកម្មភាពដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ង- ការពារប្រយោជន៍ជាតិនិងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សានិងគ្រប់គ្រងធនធានធម្មជាតិ លម្អបៃតង មិនបំពុលឬមិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

ច- ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យាព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ឆ- ប្តឹងឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ ដែលនៅជិតបំផុតក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើសការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា ១៥.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់អត្តលេខ និងពាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

ឯកសណ្ឋានរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៦.-**

មគ្គុទ្ទេសក៍ទេសចរណ៍ណាម្នាក់ដែលគិតថាបានទទួលរងគ្រោះដោយសារសេចក្តីសម្រេចរបស់ក្រសួងទេសចរណ៍ឬរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបដិសេធ ការព្យួរ ការលុបចោល ការបញ្ចុះថ្នាក់ ឬការសម្រេចដែលមានការពាក់ព័ន្ធផ្សេងៗដូចមានចែងក្នុងមាត្រា២៣ មាត្រា២៤ និងមាត្រា២៥ នៃ

អនុក្រឹត្យនេះ មានសិទ្ធិធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចណាមួយដូចរៀបរាប់ខាងលើ។ បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្តីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ។

**មាត្រា ១៧.-**

ក្រសួងទេសចរណ៍ត្រូវបំផុសនិងជួយរៀបចំបង្កើតសមាគមមគ្គុទ្ទេសក៍ទេសចរណ៍នៅថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ព្រមទាំងបង្កលក្ខណៈឲ្យសមាគមនេះរៀបចំបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវដាក់ឆ្លងសេចក្តីព្រាងក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈនេះទៅក្រសួងទេសចរណ៍ដើម្បីពិនិត្យនិងយល់ព្រម។

## ផ្នែកទី៣
## ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៨.-**

ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។

មុខវិជ្ជាក្នុងការប្រឡងជ្រើសរើស ដើម្បីទទួលបានការបណ្តុះបណ្តាលជាមគ្គុទ្ទេសក៍ទេសចរណ៍ដែលត្រូវតែមានជាការចាំបាច់រួមមាន៖

ក- ភាសាបរទេសមួយ។

ខ- ភូមិសាស្ត្រប្រទេសកម្ពុជា។

គ- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

ឃ- ចំណេះដឹងទូទៅអំពីទេសចរណ៍ សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសង្គមរបស់កម្ពុជា។

ក្រសួងទេសចរណ៍អាចបំពេញបន្ថែមមុខវិជ្ជាមួយចំនួនទៀតស្របតាមការចាំបាច់ឬការតម្រូវដែលមានកំណត់ក្នុងផែនការអភិវឌ្ឍទេសចរណ៍។

លក្ខខណ្ឌនិងនីតិវិធីនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៩.-**

ក្រសួងទេសចរណ៍អាចធ្វើសហការជាមួយសាលាវិជ្ជាជីវៈទេសចរណ៍រដ្ឋឬឯកជនក្នុងការបណ្តុះ

បណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍។ ការរៀបចំកម្មវិធីសិក្សានិងគ្រូសម្រាប់ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានពិនិត្យនិងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**មាត្រា ២០.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំផែនការជ្រើសរើស ការបណ្តុះបណ្តាល និងក្រិតការមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ស្របតាមផែនការអភិវឌ្ឍទេសចរណ៍។

គម្រោងការងារជ្រើសរើស ការបណ្តុះបណ្តាល និងក្រិតការមគ្គុទ្ទេសក៍ទេសចរណ៍ ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២១.-**

ក្រសួងទេសចរណ៍អាចអនុញ្ញាតឲ្យមានអ្នកបកប្រែភាសាបំពេញភារកិច្ចជាមួយនឹងមគ្គុទ្ទេសក៍ទេសចរណ៍បាន ដើម្បីដោះស្រាយជាបណ្តោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសារបស់ភ្ញៀវ។

ការគ្រប់គ្រងអ្នកបកប្រែភាសា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២២.-**

អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ឬស្ថាប័នសាមីដោយមានកិច្ចសហការជាមួយក្រសួងទេសចរណ៍ក្នុងការបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ចនិងទេសចរណ៍។

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានទទួលស្គាល់ជាមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដោយមានវិញ្ញាបនបត្រជំនាញដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី។ មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញការងារបន្ថែមនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា ២៣.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការលុបចោលអាជ្ញាប័ណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ណាដែលត្រូវបានតុលាការសម្រេចជាស្ថាពរថាមានទោសពីបទឧក្រិដ្ឋឬពីបទមជ្ឈិម។

**មាត្រា ២៤.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើការព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជាបន្ទាន់ ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍មានបញ្ហាកាយសម្បទាឬអសមត្ថភាពផ្នែកបញ្ញាសម្បទា ឬមានជំងឺឆ្លងធ្ងន់ធ្ងរដែលមានលក្ខណៈអាចប៉ះពាល់ដល់សុខភាពទេសចរក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណ។

**មាត្រា ២៥.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍បានផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំ ឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ។ ក្នុងករណីនេះក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ៣០(សាមសិប)ថ្ងៃជាមុន ទៅកាន់ម្ចាស់អាជ្ញាបណ្ណ និងត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់។

**មាត្រា ២៦.-**

លក្ខខណ្ឌនិងនីតិវិធីនៃការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២៧.-**

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ឬការពិន័យអន្តរការណ៍មិនធ្វើឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា ២៨.-**

បុគ្គលណាដែលប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា ២៩.-**

ជនណាដែលក្លែងអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា ៣០.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត កន្លងមកដែលនៅមានសុពលភាព ត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧៦. អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ទៅក្នុងឋានន្តរស័ក្តិ **ក្រមការ** នៃក្របខ័ណ្ឌមន្ត្រីក្រមការចំនួន ០២រូប គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១១ តទៅ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|---|
| ១ | ឯក សុផាន | ប | ០៥.០៦.១៩៨៤ | មន្ត្រីក្រមការថ្នាក់លេខ១៤ |
| ២ | កេត ផាន់ណារី | ស | ២២.០៥.១៩៨៦ | មន្ត្រីក្រមការថ្នាក់លេខ១៤ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៦៧ . អនក្រ - បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន ០២រូប នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- លោក ផៃ សុភាព ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី ញឹម វណ្ណដា

២- លោក ខុច ធី ជំនួយការរដ្ឋបាលនិងហិរញ្ញវត្ថុគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៦៨. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយប្រាក់ស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន ០៤រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយអភិវឌ្ឍន៍ វិស័យសិក្សាធិការ និងសង្គមកិច្ច កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **វូ ជូហា** | Mr. Woo, Joo Ha |
| ២- | លោក | **ងឿន ដាលស៊ូ** | Mr. Weon, Dal Soo |
| ៣- | លោក | **ក្វាង បុកផាក** | Mr. Kwang-Bok, Park |
| ៤- | លោក | **អ៊ឹម តែគីន** | Mr. Eum, Tae Keun |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **ឡាញ់ នី** អត្តលេខ ០០១៦៧៧ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

